ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្តបាត់ដំបង

លេខ÷ ......០៨២៦..... សហវ.បប

# របាយការណ៍ ស្តីពី
# វឌ្ឍនភាព នៃការអនុវត្តសកម្មភាព
# ប្រចាំខែសីហា ឆ្នាំ២០២៦ និងទិសដៅអនុវត្តបន្ត
# របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
# ខេត្តបាត់ដំបង

**ការិយាល័យរដ្ឋបាល ហិរញ្ញវត្ថុ និងបុគ្គលិក**

ថ្ងៃ អង្គារ ៥កើត ខែ ស្រាពណ៍ ឆ្នាំមមី អដ្ឋស័ក ព.ស ២៥៧០

បាត់ដំបង, ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០២៦

# មាតិកា


១. សេចក្តីផ្តើម ........ 1

២. វឌ្ឍនភាពនៃការអនុវត្តការងារប្រចាំខែ សីហា ឆ្នាំ២០២៦ ........ 1

**ក. ការិយាល័យរដ្ឋបាល ហិរញ្ញវត្ថុ និងបុគ្គលិក (គិតត្រឹមថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៦)** ........ 1

**ក.១. ការងាររដ្ឋបាល** ........ 1

**ក.២. ការងារហិរញ្ញវត្ថុ** ........ 3

**ក.៣. ការងារបុគ្គលិក** ........ 3

**ក.៤. ការងារប្រព័ន្ធ** FMIS ........ 3

**ខ. ការិយាល័យស្ថិតិ និងសេដ្ឋកិច្ចមូលដ្ឋាន (គិតត្រឹមថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៦)** ........ 4

**ខ.១. ការងាររដ្ឋបាល** ........ 4

**ខ.២. ការងារស្ថិតិ និងសេដ្ឋកិច្ចមូលដ្ឋាន** ........ 4

**ខ.៤. ការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៦** ........ 6

**ខ.៥. ការងារគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម** ........ 7

**គ. ការិយាល័យថវិកា (គិតត្រឹមថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៦)** ........ 7

**គ.១. ការអនុវត្តចំណូលមិនមែនសារពើពន្ធ(លើកលែងចំណូលពន្ធដារ និងគយ រដ្ឋាករ គិតត្រឹមថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០២៦)÷** ........ 7

**គ.២.ការអនុវត្តចំណាយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (គិតត្រឹមថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៦)÷** ........ 9

**គ.៣ .សកម្មភាពការងារចំណាយថវិកាថ្នាក់ជាតិ (មន្ទីរជំនាញ): (គិតត្រឹម ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៦ )** .. 10

**គ.៤.សកម្មភាពការងារ ចំណាយថវិការដ្ឋបាលថ្នាក់ក្រោមជាតិ(សាលាខេត្ត ក្រុង/ ស្រុក) : (គិតត្រឹមថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០២៦)** ........ 10

**ឃ. ការិយាល័យទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ (គិតត្រឹមថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៦)** ........ 11

**ង. ការិយាល័យលទ្ធកម្មសាធារណៈ (គិតត្រឹមថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៦)** ........ 12

៣. បញ្ហាប្រឈម និងសំណើដំណោះស្រាយ ប្រចាំខែ សីហា ឆ្នាំ២០២៦ ........ 14

៤. ទិសដៅបន្តអនុវត្តក្នុងខែ កញ្ញា ឆ្នាំ២០២៦ ........ 15

៥. សំណូមពរ ........

៦. សេចក្តីសន្និដ្ឋាន ........

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្តបាត់ដំបង

**សូមគោរពជូន**

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**តាមរយៈឯកឧត្តមអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**កម្មវត្ថុ:** របាយការណ៍ស្តីពីវឌ្ឍនភាព នៃការអនុវត្តសកម្មភាពប្រចាំខែ សីហា ឆ្នាំ២០២៦ និងទិសដៅអនុវត្តបន្ត របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបាត់ដំបង

តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទសូមជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** ដោយសង្ខេបនូវវឌ្ឍនភាពនៃសកម្មភាពដែលមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រេចបានក្នុងខែសីហា ឆ្នាំ២០២៦ និងទិសដៅអនុវត្តបន្ត មានដូចខាងក្រោម:

មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបាត់ដំបង ជាអង្គភាពរដ្ឋបាលសេដ្ឋកិច្ចបំពេញមុខងារ ជាតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការងារសម្របសម្រួលអង្គភាពថ្នាក់មូលដ្ឋានរបស់ក្រសួង អនុវត្តភារកិច្ចគ្រប់គ្រងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅរដ្ឋបាលថ្នាក់ក្រោមជាតិមានការិយាល័យចំណុះចំនួន ០៥ អនុវត្តសកម្មភាពតាមវិស័យសម្រេចជាលទ្ធផលរួមដូចខាងក្រោម៖

## ១. សេចក្តីផ្តើម

ទិន្នន័យខែ សីហា ឆ្នាំ២០២៦ មន្ទីរ មានមន្ត្រីរាជការស៊ីវិល មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកជាប់កិច្ចសន្យាសរុបចំនួន ៣៧នាក់ ស្ត្រី ១៧នាក់ ដឹកនាំ ដោយប្រធានមន្ទីរ ០១នាក់ ទទួលបន្ទុកក្តាប់រួម អនុប្រធានមន្ទីរ ០៣នាក់ ស្រី ០១រូប និងប្រធានការិយាល័យ ០៥នាក់ ស្ត្រី ០២នាក់។ ក្នុងនោះអនុប្រធានការិយាល័យមានចំនួន ១០នាក់ ស្រី ចំនួន ០៥នាក់។ មន្ត្រីរាជការស៊ីវិល សរុប ២៩រូប ស្រី ១២រូប និងមន្ត្រីជាប់កិច្ចសន្យា ចំនួន ០៦រូប ស្រី ០៥នាក់ និងបុគ្គលិកកិច្ចសន្យា ចំនួន ០២រូប ស្រី ០០នាក់ ។

## ២. វឌ្ឍនភាពនៃការអនុវត្តការងារប្រចាំខែ សីហា ឆ្នាំ២០២៦

### ក. ការិយាល័យរដ្ឋបាល ហិរញ្ញវត្ថុ និងបុគ្គលិក (គិតត្រឹមថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៦)

#### ក.១. ការងាររដ្ឋបាល

- **លិខិតចូលចំនួន** ៖ ១៨៨ ច្បាប់

- **លិខិតចេញចំនួន** ៖ ២៣៨ ច្បាប់
- **ថ្នាក់ជាតិចំនួន** ៖ ០៩៤ ច្បាប់
- **អាណត្តិថ្នាក់ក្រោមជាតិចំនួន** ៖ ០៥៥ ច្បាប់
- បានបូកសរុបការងារថ្នាក់ដឹកនាំនិងមន្ត្រីរាជការដែលបានចូលរួមកិច្ចប្រជុំសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងសកម្មភាពសង្គមនានា នៅមន្ទីរ ក្នុងខេត្តចំនួន ១០ លើក (ក្នុងខេត្តគ្មានបេសកកម្មចំនួន ០៦ លើក, បេសកកម្មក្នុងខេត្តចំនួន ០១ លើក, និងបេសកកម្មឆ្លងខេត្តចំនួន ០៣ លើក)
- បានរៀបចំកិច្ចប្រជុំផ្ទាល់ ០២លើក និងអនឡាញ ០២លើក នៅសាលប្រជុំមន្ទីរសរុប ចំនួន ០៤ លើក ។
- បានរៀបចំ និងចូលរួមធ្វើពលកម្មសម្អាតបរិវេណជុំវិញមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ប្រចាំខែសីហា ឆ្នាំ ២០២៦។
- បានរៀបចំ និងចូលរួមគោរពទង់ជាតិប្រចាំសប្តាហ៍ក្នុងខែសីហា ឆ្នាំ២០២៦ នៅបរិវេណខាងមុខដង ទង់ជាតិមន្ទីរ។
- បានចូលរួមកិច្ចប្រជុំពិភាក្សាស្តីពី ការសិក្សាវាយតម្លៃលើស្ថានភាពផលិតកម្ម ចំណីសត្វ និងជីកសិកម្ម សម្រាប់តម្រូវការក្នុងស្រុកនិងការនាំចេញ នាព្រឹកថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៦។
- បានទទួល និងសម្របសម្រួលប្រតិភូក្រសួងចុះត្រួតពិនិត្យបញ្ជីសារពើភណ្ឌ។
- បានចូលរួមពិធីបុណ្យប្រគេនទៀនព្រះវស្សានិងទេយ្យវត្ថុដល់ព្រះសង្ឃចំនួន០៤វត្តៈនិងវេបន្តប្រគេន ព្រះសង្ឃចំនួន១២វត្ត នៅប៉ែកខាងក្រោម នាព្រឹក ៣១ /កក្កដា /២០២៦ នៅវត្តព្រះពុទ្ធមានបុណ្យ ។
- បានចូលរួមកិច្ចប្រជុំជីវភាពផ្ទៃក្នុងមន្ទីរ និងបូកសរុបវឌ្ឍនភាពការងារប្រចាំខែកក្កដា ឆ្នាំ២០២៦។ កិច្ចប្រជុំនេះដែរ មានគោលបំណង៖ ពង្រឹងវិន័យការងារប្រចាំថ្ងៃ, បញ្ហាប្រឈមនានា និងផ្សេងៗ។
- បានសម្របសម្រួល និងរៀបចំសុន្ទរកថាស្វាគមន៍ នៃកិច្ចប្រជុំពិភាក្សា ដើម្បីសិក្សាពីបញ្ហាប្រឈមក្នុងការ រៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ ២០២៥មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ជូនថ្នាក់ដឹកនាំ។
- បានចូលរួមកិច្ចប្រជុំស្តីពី ការចុះតាមដាន និងស្រង់ថ្លៃទំនិញ និងសេវាលើទីផ្សារតាមបណ្តាខេត្តប្រចាំ ត្រីមាស សម្រាប់ឆ្នាំ២០២៦ និងចុះស្រង់ថ្លៃទំនិញ និងសេវាដោយផ្ទាល់។
- បានរៀបចំលិខិតជូនដំណឹងមរណភាព និងចូលរួមរំលែកទុក្ខគ្រួសាររបស់លោកស្រី រស់ សុខុម និវត្តជន នៃមន្ទីរសហវ។

❖ **ការងារបណ្ណសារ**

**១. ឯកសារតម្កល់**

- បានជ្រើសរើសឯកសារសម្រាប់តម្កល់ និងសរសេរកូដក្រោយពេលស្កេនរួចក្នុង១ច្បាប់ៗបាន រៀបចំរក្សាទុកក្នុង profile មួយដែលក្រសួងបានណែនាំ (ឯកសារទាំងអស់ គឺជាឯកសាររបស់ អង្គភាពសាមី ដែលមន្ទីរយើងជាអ្នកផលិតផ្ទាល់)។

**២. ការងារស្កេនឯកសារ និងបញ្ចូលប្រព័ន្ធ(សម្រាប់បញ្ចូលទៅក្នុងប្រព័ន្ធ)**

- បានស្កេនឯកសារ និងបញ្ចូលក្នុងប្រព័ន្ធ។

៣. ការងារជម្រះឯកសារ

- បានបញ្ចូលក្នុងតារាងជម្រះ។

៤. ការងារបញ្ជីវត្តមាន

- បានរៀបចំរបាយការណ៍សម្រង់វត្តមានសរុបប្រចាំខែកក្កដា ជូនអគ្គលេខាធិការដ្ឋាននៃក្រសួងសហវ។
- បានរៀបចំរបាយការណ៍សម្រង់វត្តមានប្រចាំសប្តាហ៍ទី១,២និង៣ ប្រចាំខែសីហា ឆ្នាំ២០២៦។

**ក.២. ការងារហិរញ្ញវត្ថុ**

- បានរៀបចំអាណត្តិថ្លៃប្រើប្រាស់អគ្គិសនីប្រចាំខែកក្កដា ឆ្នាំ២០២៦ របស់មន្ទីរសហវ។
- បានរៀបចំអាណត្តិទូទាត់ថ្លៃប្រើប្រាស់ទឹកប្រចាំខែកក្កដា ឆ្នាំ២០២៦ របស់មន្ទីរសហវ
- បានរៀបចំអាណត្តិទូទាត់សោហ៊ុយបេសកកម្មសម្រាប់ខែមីនាដល់ខែកក្កដា ឆ្នាំ២០២៦ ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃមន្ទីរសហវ។
- បានរៀបចំរបាយការណ៍ចំណាយថវិកាប្រចាំខែកក្កដារបស់មន្ទីរ។

**ក.៣. ការងារបុគ្គលិក**

- បានរៀបចំលិខិតបេសកកម្មចំនួន ៧ លើកជូនថ្នាក់ដឹកនាំនិងមន្ត្រីជំនាញចូលរួមកិច្ចប្រជុំឆ្លងខេត្តនិងក្នុងខេត្ត ១០ លើក។
- បានរៀបចំសំណើសុំច្បាប់ឈប់សម្រាកដោយស្ថិតក្នុងភាពទំនេរគ្មានបៀវត្សចំនួន០១ឆ្នាំ(មួយឆ្នាំ)ជូនមន្ត្រីរាជការចំនួន ០១រូប នៃមន្ទីរសហវ។
- បានរៀបចំសំណើសំណើសុំផ្តល់ជូនសមាសភាពថ្នាក់ដឹកនាំ និងមន្ត្រីជំនាញចំនួន ០៣រូប ដើម្បីចូលរួមកម្មវិធី "វេទិកាបរធនបាលកិច្ចឆ្នាំ២០២៦" ក្រោមមូលបទ "បរធនបាលកិច្ចក្នុងជវភាពនៃប្រព័ន្ធតួអង្គតែមួយ និងសមិទ្ធផលក្នុងរយៈពេល ៥ឆ្នាំ"។
- បានរៀបចំបញ្ជីសម្រង់បម្រែបម្រួលសមាសភាពបុគ្គលិកជាប់កិច្ចសន្យាចំនួន ០១រូប ដែលត្រូវលើកប្រាក់ឧបត្ថម្ភជីវភាពចាប់ពីខែមីនា ឆ្នាំ២០២៦ របស់មន្ទីរសហវ.ខបប។
- បានរៀបចំសំណើសុំដំឡើងឋានន្តរស័ក្តិ-ថ្នាក់តាមវេនអតីតភាពការងារជូនមន្ត្រីរាជការចំនួន០២នាក់ ក្នុងឆ្នាំ២០២៧។
- បានស្នើសុំប្រាក់ឧបត្ថម្ភសង្គហៈមិត្តជូននិវត្តជនចំនួន ០២រូប បញ្ចូលសមាជិកនិវត្តជនថ្មីចំនួន ០១រូប និងស្នើសុំកាតថ្មីជូននិវត្តជនចំនួន ០១រូប។

**ក.៤. ការងារប្រព័ន្ធ** FMIS

- បានចុះកិច្ចលទ្ធកម្មចំនួន ១គម្រោងជូនសាលាពេទ្យ។
- បានចុះកិច្ចលទ្ធកម្ម **០៣ គម្រោង** ជូនមន្ទីរសុខាភិបាល។

## ២. ការិយាល័យស្ថិតិ និងសេដ្ឋកិច្ចមូលដ្ឋាន (គិតត្រឹមថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៦)

### ២.១. ការងាររដ្ឋបាល

- ថ្នាក់ដឹកនាំ និងមន្ត្រីរាជការការិយាល័យ បានចូលរួមសកម្មភាពសង្គម កិច្ចប្រជុំផ្ទាល់ និងអនឡាញ ចំនួន ១៣ លើក បូកយោង(មករា-សីហា) ចំនួន ៨៧ លើក ។
- បានចូលរួមគោរពទង់ជាតិប្រចាំសប្តាហ៍ទី១-២ ខែ សីហា ឆ្នាំ២០២៦ នៅខាងមុខបរិវេណខាងមុខដងទង់ជាតិ។
- បានរៀបចំរបាយការណ៍វឌ្ឍនភាពការងារស្ថិតិ និងសេដ្ឋកិច្ចមូលដ្ឋានប្រចាំខែ សីហា ឆ្នាំ២០២៦៦ ជូនការិយាល័យរដ្ឋបាល ហិរញ្ញវត្ថុ និងបុគ្គលិករួចរាល់ ។

### ២.២. ការងារស្ថិតិ និងសេដ្ឋកិច្ចមូលដ្ឋាន

### ២.២.១. មគ្គុទេសសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ២០២៦

- បានទទួលទិន្នន័យពីមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ធនាគារខេត្ត, មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត, មន្ទីរការងារ និងបណ្តុះបណ្តាល, មន្ទីរអប់រំ យុវជន និងកីឡា, មន្ទីរផែនការខេត្ត, មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត, រដ្ឋាករទឹកបាត់ដំបង, មន្ទីរប៉ៃប្រសនីយ៍ និងទូរគមនាគមន៍, មន្ទីរធនធានទឹក និងឧតុនិយមខេត្ត, សាខាធនាគារជាតិបាត់ដំបង, អគ្គីសនីបាត់ដំបង បូកយោងចំនួន ១២អង្គភាព នៅខ្វះ ០១អង្គភាពទៀត។
- បានផ្ញើសំណើសុំផ្ទៀងផ្ទាត់ ផ្តល់ទិន្នន័យ និងភ្ជាប់រូបភាព មគ្គុទេសក៍សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆមាសទី១ ឆ្នាំ ២០២៦ ទៅមន្ទីរ អង្គភាពពាក់ព័ន្ធ ចំនួន ១៨ អង្គភាព ជា soft និង Hard នៅសល់ ០០អង្គភាព សរុប ១៨អង្គភាព។
- កំពុងធ្វើបច្ចុប្បន្នភាពតារាងឈ្មោះអង្គភាព និងបរិយាយការងារ ដើម្បីសុំផ្ទៀងផ្ទាត់ ផ្តល់ទិន្នន័យ និងភ្ជាប់រូបភាព មគ្គុទេសក៍សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខែ ត្រីមាស ឆមាស និងឆ្នាំ ពីគ្រប់អង្គភាពពាក់ព័ន្ធ ចំនួន ១៨អង្គភាព។
- កំពុងធ្វើបច្ចុប្បន្នភាពទិន្នន័យ ម៉ាំង I-V។ សម្រេចលទ្ធផលបាន 78% នៃផែនការសកម្មភាព។ ទិសដៅបន្ត៖ បន្តប្រមូល បូកសរុប និងរក្សាទុកទិន្នន័យ។ ក្រសួងប្រមូលថ្ងៃទី ៣០ ខែ សីហា ២០២៦។

### ២.២.២. សម្រង់ថ្លៃទំនិញជាអាហារមូលដ្ឋានប្រចាំសប្តាហ៍ និងខែ

- បានរៀបចំសំណើសុំ ចំនួន ០៣ ផ្ញើជូនលោកប្រធានមន្ទីរពាណិជ្ជកម្មខេត្ត មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត" ។

  1. សំណើសុំ "របាយការណ៍សន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សារ ប្រចាំសប្តាហ៍ និងប្រចាំខែ ឆ្នាំ ២០២៦ របស់មន្ទីរពាណិជ្ជកម្មខេត្ត"

  2. សំណើសុំកិច្ចសហការណ៍ពីក្រុមការងារនៃមន្ទីរពាណិជ្ជកម្មខេត្ត ដើម្បីចុះស្រង់ "ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សារ ប្រចាំសប្តាហ៍" ជាមួយក្រុមការងារនៃមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត។

  3. សំណើសុំ "ព័ត៌មាន តម្លៃសត្វ សាច់ និងផលិតផលសត្វ ប្រចាំសប្តាហ៍ និងប្រចាំខែឆ្នាំ២០២៦ របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត។

- បានទទួល "របាយការណ៍សន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សារ ប្រចាំសប្តាហ៍ និងប្រចាំខែ ឆ្នាំ ២០២៦ របស់មន្ទីរពាណិជ្ជកម្មខេត្ត"។ "ព័ត៌មាន តម្លៃសត្វ សាច់ និងផលិតផលសត្វប្រចាំសប្តាហ៍ និងប្រចាំ

ខែឆ្នាំ២០២៦ របស់មន្ទីរសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត។ "ទិន្នន័យថ្លៃផ្សេងទៀត" ប្រចាំសប្ដាហ៍ និងប្រចាំខែ ឆ្នាំ២០២៦ របស់មន្ទីរផែនការខេត្ត។

- បានរៀបចំតារាងថ្លៃទំនិញជាអាហារមូលដ្ឋានប្រចាំសប្ដាហ៍ទី១ ខែ សីហា ឆ្នាំ២០២៦ របស់ខេត្តបាត់ដំបង ជូនឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- បាន "ចុះស្រង់ថ្លៃទំនិញជាអាហារមូលដ្ឋានប្រចាំសប្ដាហ៍ ទី១ខែសីហា ឆ្នាំ២០២៦របស់ខេត្តបាត់ដំបង" នាព្រឹកថ្ងៃ សុក្រ ទី ០៧ ខែ សីហា ២០២៦ នៅផ្សារថ្មីខេត្តបាត់ដំបង។ គោលបំណងៈតាមដានបម្រែបម្រួលតម្លៃ, វាស់វែងកម្រិតអតិផរណា,វាយតម្លៃការផ្គត់ផ្គង់ និងរាយការណ៍ជូនអគ្គនាយកដ្ឋានគោលនយោបាយក្រសហវ។ បានរៀបចំតារាងថ្លៃទំនិញជាអាហារមូលដ្ឋានប្រចាំសប្ដាហ៍ទី១ ខែ សីហា ឆ្នាំ២០២៦របស់ខេត្តបាត់ដំបង ជូនឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ខ.២.៣. ការងារជាមួយមន្ទីរផែនការខេត្ត**

- បានបន្តប្រមូល និងឆ្លើយតបនូវសំណួរបច្ចេកទេសនានាជាមួយ ១.តំណាងមន្ទីរកសិកកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តបាត់ដំបង ២.តំណាងមន្ទីររៀបចំ ដែនដី នគរូបនីយកម្ម សុរិយោដី និងសំណង់ខេត្តបាត់ដំបង ៣.តំណាងមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ខេត្តបាត់ដំបង ៤.តំណាងមន្ទីរទេសចរណ៍ខេត្តបាត់ដំបង ក្នុងការបំពេញនូវតារាងទិន្នន័យស្ថិតិទាំងតាម វិស័យសម្រាប់ឆ្នាំ២០២៥ និងឆមាសទី១ ឆ្នាំ២០២៦ និងស្នើសុំរបាយការណ៍បូកសរុបប្រចាំឆ្នាំ២០២៥ និងប្រចាំឆមាសទី១ ឆ្នាំ២០២៦ ចំនួន១ច្បាប់។ បានប្រមូលទិន្នន័យ និងបានផ្ញើជូនអគ្គគោលនយោបាយបានគ្រប់ចំនួន។

**ខ.២.៤. ព័ត៌មានសេដ្ឋកិច្ច និងសង្គមខេត្តបាត់ដំបងឆ្នាំ២០២៦**

- បានចូលរួម សម្របសម្រួលការចុះជួបសហគ្រាស ប្រមូលទិន្នន័យពីមន្ទីរកសិកម្ម និងមន្ទីរឧស្សាហ៍កម្មក្រោយ «ការសិក្សាវាយតម្លៃលើស្ថានភាពផលិតកម្មចំណីសត្វ និងជីកសិកម្មសម្រាប់តម្រូវការក្នុងស្រុក និងការនាំចេញ» នៅថ្ងៃទី២២ ខែកក្កដា ២០២៦ វេលាម៉ោង 8:30 នៅសាលប្រជុំមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបាត់ដំបង ជាមួយតំណាងមន្ទីរកសិកកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តបាត់ដំបង និង តំណាងមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យាខេត្តបាត់ដំបង និងតំណាងសហគ្រាសលោកប៊ុត សុធី ផលិតជីកសិកម្ម និងអគ្គនាយកដ្ឋានគោលនយោបាយនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ខ.២.៥. ការងារជាមួយមន្ទីរផែនការខេត្ត**

- បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការប្រជាជន និងអភិវឌ្ឍន៍ខេត្តបាត់ដំបង ដើម្បីផ្សព្វផ្សាយ និងប្រមូលធាតុចូលសម្រាប់រៀបចំផែនការសកម្មភាពអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រកម្ពុជាឆ្នាំ២០២៤-២០៣០ ខេត្តបាត់ដំបង។ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពុំមានទិន្នន័យពាក់ព័ន្ធនឹងសកម្មភាពនេះទេ។

### ២.២.៦. ទិដ្ឋភាពសង្គម សេដ្ឋកិច្ច និងការវិភាគ ភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែង (SWOT) ដើម្បីកំណត់ពីសក្កានុពល និងបញ្ហាប្រឈមក្នុងកិច្ចអភិវឌ្ឍន៍របស់ខេត្តបាត់ដំបង ឆ្នាំ២០២៦

- កំពុងរៀបចំ "ទិដ្ឋភាពសង្គម សេដ្ឋកិច្ច និងការវិភាគ ភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែង (SWOT) ដើម្បីកំណត់ពីសក្កានុពល និងបញ្ហាប្រឈមក្នុងកិច្ចអភិវឌ្ឍន៍របស់ខេត្តបាត់ដំបង ឆ្នាំ២០២៦" តាមទម្រង់ថ្មី បានចំនួន ៨៩%នៃផែនការសកម្មភាពឆ្នាំ២០២៦។
- កំពុងបូកសរុបទិន្នន័យព័ត៌មានសេដ្ឋកិច្ច និងសង្គម ខេត្តបាត់ដំបងឆ្នាំ២០២៦។ សម្រេចលទ្ធផលបាន 66% នៃផែនការសកម្មភាព។ បានទទួលទិន្នន័យ ត្រីមាសទី១ ឆ្នាំ២០២៦ ពីមន្ទីរកសិកម្ម រុកប្រមាញ់ និងនេសាទខេត្ត និងទិន្នន័យ ត្រីមាសទី១ និងទី២ ឆ្នាំ២០២៦ ពីមន្ទីរផែនការខេត្តបាត់ដំបង។ នៅសល់ទិន្នន័យពី ១០ អង្គភាព ដែលពាក់ព័ន្ធ។

### ២.៣. ការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៦

- FMIS: បានបញ្ចូលការបញ្ជាទិញកិច្ចលទ្ធកម្មរបស់មន្ទីរជំនាញ ចំនួន ៣៥គម្រោង បូកយោង (មករា-សីហា) ចំនួន ៣០២គម្រោង នៅសល់ 00គម្រោង។
- មន្ទីរមានកុំព្យូទ័រប្រព័ន្ធ FMIS សរុបចំនួន ១៤គ្រឿង និងមានអ្នកអនុម័ត និងអ្នកប្រើប្រាស់ប្រព័ន្ធសរុបចំនួន ១៧នាក់ ស្រី ១០នាក់។ មន្ទីរបានជម្រុះកុំព្យូទ័រប្រព័ន្ធ FMIS ចំនួន ០៩គ្រឿង និងទទួលបានកុំព្យូទ័រប្រព័ន្ធ FMIS ថ្មី ចំនួន ០៩គ្រឿង សរុបចំនួន ១៤គ្រឿង ដដែល។
- ការងារបញ្ចូលមុខងារលទ្ធកម្មពេញលេញ(PR)ក្នុងប្រព័ន្ធ FMIS៖ កំពុងរៀបចំផែនការលទ្ធកម្មឆ្នាំ២០២៧ មានចំនួន១៤គម្រោង។
- ការងារបញ្ចូលផែនការថវិកា(BSP)និងផែនការចំណូលចំណាយថវិកាកម្មវិធីឆ្នាំ២០២៧៖បានរៀបចំផែនការយុទ្ធសាស្ត្រថវិកា ២០២៧-២០២៩។
- ការងារអនុម័តការបញ្ចូលអាណត្តិ និងទាញរបាយការណ៍ចំណូល-ចំណាយចរន្តតាមប្រព័ន្ធOnlineរបស់សាកលវិទ្យាល័យជាតិបាត់ដំបង (ដែលជាគ្រឹះស្ថានសាធារណៈរដ្ឋបាល)៖ បានត្រួតពិនិត្យ និងអនុម័តអាណត្តិចំណាយក្នុងខែ សីហា ២០២៦ របស់សាកលវិទ្យាល័យជាតិបាត់ដំបង។
- បានរៀបចំសំណើសុំផ្លាស់ប្តូរទីតាំងកុំព្យូទ័រប្រព័ន្ធចំនួន ០២គ្រឿង និងទទួលការអនុម័តលើសំណើសុំបន្ថែមមុខងារ របស់ អ៊ឹម សៀវលី និងបានរៀបចំសំណើមោឃភាពការបញ្ជាទិញចំនួន ១៥គម្រោង ។

### ២.៤. ការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៦

- កំពុងតម្រូវទិន្នន័យព័ត៌មានសេដ្ឋកិច្ច និងសង្គមខេត្តបាត់ដំបងឆ្នាំ២០២៦។ទំព័រ ១០/១៥។ សម្រេចលទ្ធផលបាន 66% នៃផែនការសកម្មភាព។ បានទទួលទិន្នន័យ ត្រីមាសទី១ ឆ្នាំ២០២៦ ពីមន្ទីរកសិកម្ម រុក្ខប្រមាញ់ និងនេសាទ និងទិន្នន័យ ត្រីមាសទី១ និងទី២ ឆ្នាំ២០២៦ ពីមន្ទីរផែនការខេត្តបាត់ដំបង។
- បានចូលរួម សិក្ខាសាលាបញ្ញាបការយល់ដឹង និងកសាងសមត្ថភាព ក្នុងការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ច ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកាលពីថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០២៦ នៅសណ្ឋាគារ Courtyard ខេត្តសៀមរាប។

- កំពុងរៀបចំ "ទិដ្ឋភាពសង្គម សេដ្ឋកិច្ច និងការវិភាគ ភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែង (SWOT) ដើម្បីកំណត់ពីសក្តានុពល និងបញ្ហាប្រឈមក្នុងកិច្ចអភិវឌ្ឍន៍របស់ខេត្តបាត់ដំបង ឆ្នាំ២០២៦" តាមទម្រង់ថ្មី បានចំនួន ៨៩%នៃផែនការសកម្មភាពឆ្នាំ២០២៦។
- កំពុងរៀបចំឯកសារពាក់ព័ន្ធដើម្បីរៀបចំកិច្ចប្រជុំត្រួតពិនិត្យនិងផ្តល់យោបល់លើ ឯកសារវិភាគ SWOT ខេត្តបាត់ដំបងឆ្នាំ២០២៦ និងប្រមូលធាតុចូល ពីគ្រប់មន្ទីរ រដ្ឋបាលក្រុង ស្រុកពាក់ព័ន្ធ ដើម្បីរៀបចំការវិភាគ SWOT ខេត្តបាត់ដំបងឆ្នាំ២០២៦។ សម្រេចលទ្ធផលបាន 56%នៃផែនការសកម្មភាព។
- កំពុងបកប្រែការវិភាគ ភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមគំហែងក្នុងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចខេត្តបាត់ដំបង SWOT ឆ្នាំ២០២៥ ជាភាសាអង់គ្លេស សម្រេចលទ្ធផល56%។
- រៀបចំទិន្នន័យ ការវិភាគ ភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមគំហែងក្នុងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចខេត្តបាត់ដំបង SWOT ឆ្នាំ២០២៥ ជាទម្រង់ Microsoft Excel ដើម្បីផុសក្នុងគេហទំព័ររបស់មន្ទីរ សម្រេចលទ្ធផល 56%។

**ខ.៥. ការងារគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម**

- បានផុសរូបភាព និងវីដេអូសកម្មភាពរបស់ថ្នាក់ដឹកនាំ និងមន្ត្រីមន្ទីរ ក្នុងហ្វេសប៊ុកផេករបស់មន្ទីរ គេហទំព័រមន្ទីរនិងគ្រុបតេឡេក្រាមក្រុមការងារក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ បានផុស និងចែករំលែកនូវព័ត៌មានថ្មីៗ តាមការណែនាំរបស់រដ្ឋបាលខេត្ត។
- ការងារគេហទំព័រមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ:http://www.mefbat.gov.kh/
- បាន Update និងបញ្ចូល សកម្មភាពថ្មីៗ របស់ថ្នាក់ដឹកនាំ, មន្ត្រីរាជការ ក្នុង គេហទំព័រ Website មន្ទីរៈ គិតត្រឹម សប្តាហ៍ទី២ ខែ សីហា ២០២៦ ក្រុមការងារបានផុស អត្ថបទចំនួន ១៧អត្ថបទ បូកយោង (មករា-សីហា ) ៨៤អត្ថបទ។ មានអ្នកចូលអានចំនួន ១៧,៧៨៥(កើន ៤៥៦ ក្នុងពេល ០១ ខែ) ក្នុងនោះអ្នកចូលមើលពីកម្ពុជា ចំនួន ៨,៥៦៤ លើក, សហរដ្ឋអាមេរិកមានចំនួន ៦,៤៤០ លើក, កាណាដាចំនួន ៩៦១ លើក,ចិន ចំនួន ៥៣៦លើក, អាឡឺម៉ង់ ចំនួន ៤៣៣លើក, អែករ៉ង់ ចំនួន ៣៣៧លើក,ស៊ីងិន ចំនួន ២៦៣ លើក,បារាំង ចំនួន ១៤៥លើក ,ប៉ូឡូញ ចំនួន ៥៥ លើក និងថៃ ចំនួន ៥១លើក ។
- ការងារហ្វេសប៊ុកផេកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ថ្មីទី៣ៈការងារហ្វេសប៊ុកផេកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ថ្មីទី៣ៈ គិត ត្រឹមសប្តាហ៍ទី២ ខែ សីហា ២០២៦ មានអ្នកតាមដានផេកចំនួន ៨.១K នាក់ (កើន ១០០ នាក់ ក្នុង១ខែ), កំពុងតាមដាន ចំនួន ៩០នាក់ (កើន ១៣នាក់ ក្នុង ១ខែ)។

**គ. ការិយាល័យថវិកា (គិតត្រឹមថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៦)**

**គ.១. ការអនុវត្តចំណូលមិនមែនសារពើពន្ធ(លើកលែងចំណូលពន្ធដារ និងគយ រដ្ឋាករ គិតត្រឹមថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០២៦)÷**

- ចំណូលមិនមែនសារពើពន្ធក្នុង ខែសីហា ឆ្នាំ២០២៦ (ថវិកាថ្នាក់ជាតិ និងថវិកាថ្នាក់ក្រោមជាតិ លើកលែងចំណូលពន្ធដារ គយ រដ្ឋាករ) ក្នុងខែសរុបចំនួន **16,079,383,392 រៀល** បូកយោង (មករា-សីហា) ចំនួន **290,366,444,250រៀល** ស្មើនឹង **89.55%** នៃច្បាប់ហិរញ្ញវត្ថុចំនួន **324,262,030,000រៀល**។

- ថវិកាថ្នាក់ជាតិ(មន្ទីរជំនាញ)ក្នុងខែ សីហា ២០២៦ សរុបចំនួន **56,312,240 រៀល** បូកយោង (មករា-សីហា) ចំនួន **5,187,725,091 រៀល** ស្មើនឹង **74.97%** ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៦ ចំនួន **6,919,900,000រៀល**។
- ថវិកាថ្នាក់ក្រោមជាតិ (សាលាខេត្ត,មន្ទីរសុខាភិបាល, ក្រុង-ស្រុក,សាលារៀនក្រុង-ស្រុក)ក្នុងខែ សីហា ឆ្នាំ ២០២៦ សរុបចំនួន **16,023,071,152 រៀល** បូកយោង(មករា-សីហា) ចំនួន **285,178,719,159រៀល** ស្មើនឹង **89.86%** ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៦ចំនួន **317,342,130,000 រៀល** ។

ឯកត្តាៈរៀល

| ប្រភេទចំណូល | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០២៦(៛) | %ធៀបនឹង ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២៦ | ចំណូលបណ្តា ខែមុន(៛) | ចំណូលក្នុងខែ សីហា ២០២៦ (៛) | បូកយោងចំណូលខែមករា-ខែ សីហា ២០២៦ (៛) |
|---|---|---|---|---|---|
| **មិនមែនសារពើពន្ធសរុប** | **324,262,030,000** | **89.55%** | **274,287,060,858** | **16,079,383,392** | **290,366,444,250** |
| **ថ្នាក់ជាតិ** | **6,919,900,000** | **74.97%** | **5,131,412,851** | **56,312,240** | **5,187,725,091** |
| **ថ្នាក់ក្រោមជាតិ** | **317,342,130,000** | **89.86%** | **269,155,648,007** | **16,023,071,152** | **285,178,719,159** |
| សាលាខេត្ត | 46,849,000,000 | 59.86% | 19,247,309,709 | 8,795,687,253 | 28,042,996,962 |
| មន្ទីរសុខាភិបាល | 62,377,200,000 | 100.00% | 62,377,200,000 | - | 62,377,200,000 |
| ក្រុងស្រុក | 40,965,530,000 | 67.39% | 20,380,738,298 | 7,227,383,899 | 27,608,122,197 |
| សាលារៀន(ក្រុង-ស្រុក) | 167,150,400,000 | 100.00% | 167,150,400,000 | - | 167,150,400,000 |

ឯកត្តាៈរៀល

| បរិយាយ | ចំណូលខែ សីហា ឆ្នាំ២០២៦ | ជំ.៧០ | ជំ.៧២ | ជំ.៧៣ | ជំពូក ៧៤ | ជំពូក ៧៥ | ជំពូក ៧៦ |
|---|---|---|---|---|---|---|---|
| | | (រៀល) | (រៀល) | (រៀល) | (រៀល) | (រៀល) | (រៀល) |
| **ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ** | **16,079,383,392** | **2,085,674,529** | **83,143,611** | **551,972,545** | **11,645,940** | **13,334,000,000** | **12,946,767** |
| **ថ្នាក់ជាតិ** | **56,312,240** | - | - | **56,312,240** | - | - | - |
| **ថ្នាក់ក្រោមជាតិ** | **16,023,071,152** | **2,085,674,529** | **83,143,611** | **495,660,305** | **11,645,940** | **13,334,000,000** | **12,946,767** |
| សាលាខេត្ត | 8,795,687,253 | 2,085,674,529 | 83,143,611 | 315,223,173 | 11,645,940 | 6,300,000,000 | - |
| មន្ទីរសុខាភិបាល | - | - | - | - | - | - | - |
| ក្រុង ស្រុក | 7,227,383,899 | - | - | 180,437,132 | - | 7,034,000,000 | 12,946,767 |
| សាលារៀន (ក្រុង ស្រុក) | - | - | - | - | - | - | - |

**គ.២.ការអនុវត្តចំណាយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (គិតត្រឹមថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៦)÷**

- ចំណាយក្នុងខែ សីហា ឆ្នាំ២០២៦ សរុបចំនួន **35,514,826,430រៀល** បូកយោង(មករា-សីហា)ចំនួន **284,179,525,766រៀល** ស្មើនឹង **54.22%** ច្បាប់ហិរញ្ញវត្ថុកែតម្រូវចំនួន **524,121,825,000រៀល**។
- ថវិកាថ្នាក់ជាតិ(មន្ទីរជំនាញ)ចំណាយក្នុងខែ សីហា ឆ្នាំ ២០២៦ សរុបចំនួន **9,696,742,047រៀល** បូកយោង (មករា-សីហា) ចំនួន **104,548,135,430រៀល** ស្មើនឹង **67.03%** ធៀបនឹងច្បាប់ហិរញ្ញវត្ថុកែតម្រូវឆ្នាំ២០២៦ ចំនួន **155,974,200,000រៀល**។
- ថវិកាថ្នាក់ក្រោមជាតិ(សាលាខេត្ត,មន្ទីរសុខាភិបាល,ក្រុង-ស្រុក,សាលារៀនក្រុង-ស្រុក) ចំណាយក្នុងខែ សីហា ឆ្នាំ ២០២៦ សរុបចំនួន **25,818,084,383រៀល** បូកយោង (មករា-សីហា) ចំនួន **179,631,390,336រៀល** ស្មើនឹង **48.79%** នៃច្បាប់ហិរញ្ញវត្ថុកែតម្រូវ ចំនួន **368,147,625,000រៀល** ។

ឯកត្តា៖រៀល

| ប្រភេទចំណាយ | ច្បាប់ហិរញ្ញវត្ថុកែតម្រូវឆ្នាំ ២០២៦ (៛) | %ធៀបនឹង ច្បាប់ហិរញ្ញវត្ថុកែតម្រូវ ឆ្នាំ ២០២៦ | ចំណាយបណ្តាខែមុន (៛) | ចំណាយក្នុងខែ សីហា ឆ្នាំ២០២៦(៛) | បូកយោងចំណាយខែ មករា-សីហា ឆ្នាំ ២០២៦(៛) |
|---|---|---|---|---|---|
| **ថ្នាក់ជាតិនិងក្រោមជាតិសរុប** | **524,121,825,000** | **54.22%** | **248,664,699,336** | **35,514,826,430** | **284,179,525,766** |
| **ថ្នាក់ជាតិ** | **155,974,200,000** | **67.03%** | **94,851,393,383** | **9,696,742,047** | **104,548,135,430** |
| **ថ្នាក់ក្រោមជាតិ** | **368,147,625,000** | **48.79%** | **153,813,305,953** | **25,818,084,383** | **179,631,390,336** |
| សាលាខេត្ត | 45,961,000,000 | 60.02% | 25,957,404,174 | 1,630,567,770 | 27,587,971,944 |
| មន្ទីរសុខាភិបាល | 108,338,200,000 | 32.77% | 29,461,752,096 | 6,042,132,258 | 35,503,884,354 |
| ក្រុង ស្រុក | 42,961,530,000 | 48.54% | 16,266,311,675 | 4,585,992,810 | 20,852,304,485 |
| សាលារៀន(ក្រុង-ស្រុក) | 170,886,895,000 | 55.99% | 82,127,838,008 | 13,559,391,545 | 95,687,229,553 |

ឯកត្តា៖រៀល

| **បរិយាយ** | **ចំណាយ ខែ សីហា ឆ្នាំ ២០២៦** | ជំ.៦០ (រៀល) | ជំ.៦១ (រៀល) | ជំ.៦៤ (រៀល) | ជំ.៦២ (រៀល) | ជំ.៦៣ (រៀល) |
|---|---|---|---|---|---|---|
| **ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ** | 35,514,826,430 | 1,279,554,341 | 4,156,874,579 | 26,849,492,210 | 3,227,655,300 | 1,250,000 |
| **ថ្នាក់ជាតិ** | 9,696,742,047 | 88,255,333 | 965,276,209 | 8,641,960,505 | - | 1,250,000 |
| **ថ្នាក់ក្រោមជាតិ** | 25,818,084,383 | 1,191,299,008 | 3,191,598,370 | 18,207,531,705 | 3,227,655,300 | - |

| | | | | | | |
|---|---|---|---|---|---|---|
| សាលាខេត្ត | 1,630,567,770 | - | 114,140,000 | 474,198,770 | 1,042,229,000 | - |
| មន្ទីរសុខាភិបាល | 6,042,132,258 | 541,010,178 | 288,252,000 | 3,154,627,580 | 2,058,242,500 | - |
| ក្រុង ស្រុក | 4,585,992,810 | 197,202,430 | 2,647,099,170 | 1,649,460,210 | 92,231,000 | - |
| សាលារៀន (ក្រុង-ស្រុក) | 13,559,391,545 | 453,086,400 | 142,107,200 | 12,929,245,145 | 34,952,800 | - |

**គ.៣ .សកម្មភាពការងារចំណាយថវិកាថ្នាក់ជាតិ (មន្ទីរជំនាញ): (គិតត្រឹម ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៦ )**

- បានពិនិត្យ និងផ្តល់ទិដ្ឋាការចំណាយប្រាក់បៀវត្សមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា ប្រចាំខែសីហា ឆ្នាំ២០២៦ ជូនមន្ទីរអង្គភាពជំនាញ ទាំង២៥
- បានពិនិត្យនិងផ្តល់ទិដ្ឋាការធានាចំណាយកិច្ចលទ្ធកម្មសាធារណៈលើមុខសញ្ញាលទ្ធកម្មទំនិញ លទ្ធកម្មសំណង់ និងលទ្ធកម្មសេវាកម្ម ប្រចាំខែសីហា ឆ្នាំ២០២៦៖ អនុវត្តចំនួន 0 គម្រោង (លទ្ធកម្មទំនិញ ចំនួន 0 គម្រោង លទ្ធកម្មសំណង់ចំនួន 0 គម្រោង និងលទ្ធកម្មសេវាកម្ម ចំនួន 0 គម្រោង)
- បានពិនិត្យ និងផ្តល់ទិដ្ឋាការលើការចំណាយ រជ្ជទេយ្យបុរេប្រទាន៖
  - **លើកទី៣៖** បានអនុវត្តចំនួន 10 មន្ទីរអង្គភាពជំនាញ ស្មើនឹងទឹកប្រាក់ **166,997,500 រៀល**
- **ការងារប្រព័ន្ធ FMIS ប្រចាំខែសីហា ឆ្នាំ២០២៦៖**
  - **មុខងារគណនីត្រូវសង** AP : បានបញ្ចូលអាណត្តិបើកប្រាក់បានចំនួន ១២៣ អាណត្តិ បូកយោង ១១២៧ អាណត្តិ
  - **មុខងារការទិញ** PO:
    - បានបញ្ចូលសំណើសុំបើកសាច់ប្រាក់មុន បានចំនួន ២គម្រោង បូកយោង១៩ គម្រោង
    - បានបញ្ចូលសំណើសុំធានាចំណាយកិច្ចលទ្ធកម្ម បានចំនួន០ គម្រោង បូកយោង២៥៣ គម្រោង
  - **មុខងារវិភាជន៍ថវិកា** BA :
    - បានបញ្ចូលទិន្នន័យញែករជ្ជទេយ្យបុរេប្រទាន បានចំនួន ០អង្គភាព បូកយោង ២៥អង្គភាព
    - បានបញ្ចូលនិយ័តឥណទានថវិកា បានចំនួន ១ បូកយោង ៦។

**គ.៤.សកម្មភាពការងារ ចំណាយថវិការដ្ឋបាលថ្នាក់ក្រោមជាតិ(សាលាខេត្ត ក្រុង/ ស្រុក) : (គិតត្រឹមថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៦)**

- ពិនិត្យឯកសារ និង ចេញអាណត្តិបានចំនួន **០៦៥** បូកយោងបាន **៣៧៣**
- ធានាចំណាយក្រុង-ស្រុកចំនួន **០៣២** បូកយោង **១៣៧**
- ធានាចំណាយរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តចំនួន ០០០ បូកយោង ០៣០
- គោលការណ៍ចំណាយរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត **០២២** បូកយោង **១២៩**
- និយ័តកម្មរបស់ក្រុង-ស្រុក ០០០ បូកយោង ០០៣
- និយ័តកម្មរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត ០០០ បូកយោង ០០០
- បញ្ចូលប្រព័ន្ធ FMIS និងប្រគល់ការអនុម័តនូវ សំណើរសុំបង្កើតរជ្ជទេយ្យបុរេប្រទានឆ្នាំ២០២៦របស់រដ្ឋបាលខេត្តចំនួន០០, សំណើរសុំបង្កើតរជ្ជទេយ្យបុរេប្រទានឆ្នាំ២០២៦របស់មន្ទីរពេទ្យសុខាភិបាលនៃរដ្ឋបាលខេត្តចំនួន ០០ និងសំណើរសុំបង្កើតរជ្ជទេយ្យបុរេប្រទានឆ្នាំ២០២៦របស់មន្ទីរពេទ្យបង្អែកខេត្តចំនួន ០០ បូកយោង ០៣។

- តួនាទីអ្នកត្រួតពិនិត្យក្នុងប្រព័ន្ធ FMIS របស់រដ្ឋបាលខេត្ត,មុខងារៈ ការទិញ ត្រួតពិនិត្យក្នុងខែ ឆ្នាំ២០២៦ បានចំនួន៖
    - **ធានាចំណាយចំនួន ០០០ បូកយោង ០២៥**
    - **គោលការណ៍ចំណាយ ០០៧ បូកយោង ០៣៨**
- តួនាទីអ្នកត្រួតពិនិត្យក្នុងប្រព័ន្ធFMIS របស់រដ្ឋបាលខេត្ត,មុខងារៈគណនីត្រូវសង ត្រួតពិនិត្យក្នុងខែឆ្នាំ២០២៦ បានចំនួន៖ **បញ្ចូលអាណត្តិចំនួន ០១៩** បូកយោង **១២៤**
- ពិនិត្យឯកសារបៀវត្សប្រចាំខែ, ទូទាត់ត្រង់,ទូទាត់រដ្ឋទេយ្យបុរេប្រទាន....។ល។
- ពិនិត្យ និងចុះសំណើសុំគោលការណ៍, សំណើសុំធានាចំណាយ,សំណើសុំនិយ័តភាព,របស់រដ្ឋបាលក្រុង ស្រុក និងមន្ទីរសុខាភិបាល បញ្ចូលទៅក្នុងប្រព័ន្ធ FMIS។
- ពិនិត្យ និងចុះសំណើសុំបង្កើតរដ្ឋទេយ្យបុរេប្រទានប្រចាំឆ្នាំ ២០២៦ និងអាណត្តិរបស់មន្ទីរសុខាភិបាល បញ្ចូលទៅក្នុងប្រព័ន្ធ FMIS
- ត្រួតពិនិត្យប្រតិបត្តិការក្នុងប្រព័ន្ធ FMIS មុខងារៈ គណនីត្រូវសង (ចុះអាណត្តិ) របស់រដ្ឋបាលខេត្តបាត់ដំបង
- តួនាទីអ្នកត្រួតពិនិត្យក្នុងប្រព័ន្ធ FMIS មុខងារៈ ការទិញ (សំណើសុំធានាចំណាយ និងសំណើសុំគោលការណ៍ចំណាយ) របស់រដ្ឋបាលខេត្តបាត់ដំបង។

**ឃ. ការិយាល័យទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ (គិតត្រឹមថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៦)**

**១.ការគ្រប់គ្រងចំណូល**

**ក. ចំណូលភាស៊ីគ្រប់ប្រភេទ៖** ប្រមូល ៤១, ៤២៧,០០០ រៀល បូកយោង ៣៧២, ៥៣០, ៦២៥ រៀល

**ខ. ចំណូលបង្កាន់ដៃ៖** ប្រមូលបាន ១៧, ៧៥៣, ៨០០ រៀល បូកយោង ១៨០, ០០៧, ២១០ រៀល

**២.ការគ្រប់គ្រងបញ្ជីសារពើភណ្ឌ**

**ក.ការគ្រប់គ្រងបញ្ជីសារពើភណ្ឌឆ្នាំ ២០២៥៖**

- អង្គភាព មន្ទីរជំនាញ និងរដ្ឋបាលខេត្ត៖ បាន ០១ បូកយោង៣៤ លើ ៣៤អង្គភាព ស្មើនឹង ១០០%
- ក្រុង-ស្រុក៖ បានធ្វើ ០២ បូកយោង ០៨ លើ ១៤ អង្គភាព ស្មើនឹង ៥៧ % (ធ្វើបាន ស្រុកមោងឫស្សី, ស្រុកសំពៅលូន, ស្រុកបាណន់, ក្រុងបាត់ដំបង, ស្រុកថ្មគោល, ស្រុកភ្នំព្រឹក, ស្រុកកំរៀង, ស្រុកឯកភ្នំ)
- រដ្ឋបាលឃុំ-សង្កាត់៖ ធ្វើបាន ១៥ បូកយោង ៨១ លើ ១០៣ អង្គភាព ស្មើនឹង ៧៨% នៅសល់ ២២ ឃុំសង្កាត់

**ខ.ការគ្រប់គ្រងបញ្ជីសារពើភណ្ឌឆ្នាំគោល ២០២៤៖**

- មន្ទីរជំនាញ និងរដ្ឋបាលខេត្ត៖ ធ្វើបាន ០២ បូកយោង៣២ លើ ៣៤អង្គភាព ស្មើនឹង១០០ %
- ក្រុង-ស្រុក៖ បានធ្វើ ០៣ បូកយោង ១៤ លើ ១៤ អង្គភាព ស្មើនឹង ១០០%
- រដ្ឋបាលឃុំ-សង្កាត់៖ ធ្វើបាន ០២ បូកយោង ៩៧ លើ ១០៣អង្គភាព ស្មើនឹង ៩៤ % នៅសល់ ០៦ ឃុំសង្កាត់៖
    1. ឃុំរកា
    2. ឃុំអូរដំបង១
    3. ឃុំអូរដំបង២
    4. ឃុំចែងមានជ័យ
    5. ឃុំត្រាំង

គ.ការធ្វើប័ណ្ណកម្មសិទ្ធ

- **ចំនួនដីរដ្ឋដែលបានចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ គិតត្រឹមថ្ងៃទី ១៩ ឧសភា ២០២៦ ២៥៤៣ ទីតាំង**
- ធ្វើប័ណ្ណកម្មសិទ្ធិរួចចំនួន ១៧០៧ ទីតាំង
- មិនទាន់ធ្វើប័ណ្ណកម្មសិទ្ធចំនួន ១២៨១ ទីតាំង
- ដីបានដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិចំនួន ៨៩៧ ទីតាំង
- មិនទាន់ដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិចំនួន ២២៩ ទីតាំង
- ដីទំនាស់សរុបចំនួន ៥០ ទីតាំង
- ដីមិនអាចធ្វើបណ្ណសរុបចំនួន ១០០ ទីតាំង
- ដីកត់ត្រាស្នួនសរុបចំនួន ៥ ទីតាំង

**៣. ការគ្រប់គ្រងអាជីវកម្ម**

ក. បញ្ចាំ ៖ បានចេញលិខិតអនុញ្ញាត ០៧ បូកយោងចំនួន ៤២

ខ. ប្រាតិភោគ៖ បានចេញលិខិតអនុញ្ញាត ០៤ បូកយោងចំនួន ៣២

គ. អាជីវកម្មអភិវឌ្ឍអចលនវត្ថុ៖ បានចេញលិខិតអនុញ្ញាតចំនួន ០០ បូកយោង០០

**៤.សកម្មភាព**

- បានរៀបចំកិច្ចប្រជុំកិភាក្សាដើម្បីសិក្សាពីបញ្ហាប្រឈមក្នុងការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០២៥
- ពិនិត្យ និងទំនាក់ទំនងបញ្ជីសារពើភណ្ឌអង្គភាពមន្ទីរជំនាញ ពិសេសដោះស្រាយបញ្ហាប្រឈមក្នុងការប្រើប្រាស់ប្រព័ន្ធ SARMIS ថ្មី
- ពិនិត្យ និងទំនាក់ទំនងបញ្ជីសារពើភណ្ឌ ស្រុក និងឃុំ-សង្កាត់
- ទំនាក់ទំនងការងារគ្រប់គ្រងអាជីវកម្ម
- ទំនាក់ទំនងការងារភោសុី

**ខ. ការិយាល័យលទ្ធកម្មសាធារណៈ: (គិតត្រឹមថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៦)**

**១.ការងារលើឯកសារៈ**

- ប្រជុំវាយតំលៃអនុម័តគម្រោងជួសជុលអគារនិងចាក់បេតុងស្រុកកំរៀង ។
- ពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំអនុម័តលើកិច្ចសន្យាការងារជួសជុលផ្លូវដីសចំនួន ០១ ខ្សែ ប្រវែង ២០០០ម របស់ស្រុក សំឡូត ។
- ពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំអនុម័តលើផែនការកែតម្រូវឆ្នាំ២០២៦ របស់ស្រុក ឯកភ្នំ ។
- ពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំអនុម័តលើកិច្ចសន្យាការងារជួសជុលផ្លូវបេតុង ០១ ខ្សែ ប្រវែង ២៤២ម របស់ស្រុក ឯកភ្នំ។
- ចូលរួមប្រជុំវាយតំលៃប្រគល់ទទួលការងារជួសជួលផ្លូវបេតុង ០១ ខ្សែ ប្រវែង៥៥០ម ស្រុករតនមណ្ឌល ។

**២.ការងារណែនាំ និង បណ្តុះបណ្តាលៈ**

- គ្មាន ។

៣.ការងារចុះប្រព័ន្ធ:

- បោះពុម្ព តំលៃកិច្ចសន្យា ១៣,០០០,000 ៛ ស្រុកសង្កែ ។
- ជួសជុលឧបករណ៍បច្ចេកទេស តំលៃកិច្ចសន្យា ១០,០០០,000 ៛ ស្រុកសង្កែ ។
- បេតុង តំលៃកិច្ចសន្យា៣៨៧,៣០០,000 ៛ ស្រុករតនមណ្ឌល ។
- សូឡាតំលៃកិច្ចសន្យា ២០៤,៦០០,000 ៛ ស្រុកថ្មគោល ។
- បេតុង តំលៃកិច្ចសន្យា២៧៧,០០០,000 ៛ ស្រុកបវេល ។
- ជួសជុលផ្លូវធម្មជាតិ តំលៃកិច្ចសន្យា ២៩៨,៦០០,000 ៛ ស្រុករុក្ខគិរី ។
- ជួសជុលអគារ តំលៃកិច្ចសន្យា ១៧៩,៥៦០,000 ៛ ស្រុកសង្កែ ។
- បេតុង តំលៃកិច្ចសន្យា៥៥៨,៩០០,000 ៛ ស្រុកសំពៅលូន ។
- ស្បៀង តំលៃកិច្ចសន្យា ៣០,០០០,000 ៛ ស្រុកសង្កែ ។
- ពត័មានវិទ្យា តំលៃកិច្ចសន្យា ២៥,០០០,000 ៛ ស្រុកសង្កែ ។
- សង្ហារឹមតំលៃកិច្ចសន្យា ១៧,៩៦០,000 ៛ ស្រុកថ្មគោល ។
- ការិយាល័យតំលៃកិច្ចសន្យា ៣០,៣៧៤,000 ៛ ស្រុកថ្មគោល ។
- ប្រេង តំលៃកិច្ចសន្យា ៣៩,៩៧៨,000 ៛ ស្រុកថ្មគោល ។
- ឯកសណ្ឋាន តំលៃកិច្ចសន្យា ២៣,៩០០,000 ៛ ស្រុកថ្មគោល ។
- ឧបភោគបរិភោគតំលៃកិច្ចសន្យា៨៧,៣០០,000 ៛ ស្រុកថ្មគោល ។
- ស្បៀង តំលៃកិច្ចសន្យា ១៤,៤៦០,000 ៛ ស្រុកឯកភ្នំ ។
- បោះពុម្ព តំលៃកិច្ចសន្យា ៦,១៤៩,000 ៛ ស្រុកឯកភ្នំ ។
- ជួសជុលឧបករណ៍បច្ចេកទេស តំលៃកិច្ចសន្យា ៧,៨៤០,000 ៛ ស្រុកឯកភ្នំ។
- **ក្នុងខែសីហាទឹកប្រាក់សរុបនៃការអនុវត្តលទ្ធកម្មរបស់ក្រុងស្រុក២,២១១,៦២១,០០០ ៛ ស្មើនឹង១៨គំរោង។**
  - លទ្ធកម្មទំនិញមានចំនួន ១០គំរោង តំលៃកិច្ចសន្យាសរុប **២៨៨,១២១,០០០ ៛**
  - លទ្ធកម្មសំណង់មានចំនួន ៦គំរោង តំលៃកិច្ចសន្យាសរុប **១,៩០៥,៦៦០,០០០ ៛**
  - លទ្ធកម្មសេវាមានចំនួន ២គំរោង តំលៃកិច្ចសន្យាសរុប **១៧,៨៤០,០០០ ៛**
- **ទឹកប្រាក់សរុប ២,២១១,៦២១,០០០៛ ក្នុងខែសីហាធៀបនឹងផែនការសរុប ១៣,០៨៣,២៩០,000៛ ឆ្នាំ២០២៦ស្មើនិង១៦,៩% ។**

## ៣. បញ្ហាប្រឈម និងសំណើដំណោះស្រាយ ប្រចាំខែ សីហា ឆ្នាំ២០២៦

ទន្ទឹមនេះ សម្រាប់ការអនុវត្តការងារប្រចាំខែ សីហា ២០២៦ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបាត់ដំបងបាន ជួបប្រទះបញ្ហាប្រឈមមួយចំនួន និងស្នើសុំជាដំណោះស្រាយដូចខាងក្រោម៖

| បញ្ហាប្រឈម | សំណើដំណោះស្រាយ |
|---|---|
| **១.ការិយាល័យរដ្ឋបាល ហរិញ្ញវត្ថុ និងបុគ្គលិក៖**<br>• **ការងារបណ្ណសារ៖** ខ្វះមន្ត្រីបញ្ចូលប្រព័ន្ធបណ្ណសារ។ | -សូមស្នើសុំក្រសួងនូវមន្ត្រីជំនាញបណ្ណសារ ។ |
| **២.ការិយាល័យស្ថិតិ និងសេដ្ឋកិច្ចមូលដ្ឋាន**<br>ការងារគេហទំព័រ៖ ដូចជាការងាររៀបចំ "ទិដ្ឋភាពសង្គម-សេដ្ឋកិច្ច និងការវិភាគ ភាពខ្លាំង, ភាពខ្សោយ,ឱកាស,និងការគំរាមគំហែង ដើម្បីកំណត់ពីសក្តានុពលនិងបញ្ហាប្រឈមក្នុងកិច្ចអភិវឌ្ឍន៍របស់ខេត្តបាត់ដំបងឆ្នាំ ២០២៦ " និងព័ត៌មានទូទៅ និងសូចនាករស្តីពីស្ថានភាពសង្គម-សេដ្ឋកិច្ច ក្នុងខេត្តបាត់ដំបង ឆ្នាំ២០២៦ " និង "មគ្គុទេសក៏សេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត សម្រាប់ឆ្នាំ ២០២៦។ ក្រុមការងារមានការពិបាក ក្នុងការស្វែងរកទិន្នន័យដែលអាចទុកចិត្តបានមួយចំនួនតូចសម្រាប់ធ្វើការវិភាគ,ខ្វះខាតឧបករណ៍បច្ចេកទេស និងធនធានហិរញ្ញវត្ថុមួយចំនួន ក្នុងការពន្លឿនល្បឿន និង បង្កើនគុណភាពការងារក្នុងផ្នែកនេះ។ គេហទំព័ររបស់មន្ទីរមានភាពអាក់រអួលញឹកញាប់។ ខ្វះមន្ត្រីបច្ចេកទេស។ ខ្វះថវិកាក្នុងការBoothហ្វេសប៊ុកផេករបស់មន្ទីរ។ទិន្នន័យដែលទទួលបានពុំទាន់មានបច្ចុប្បន្នភាព(ប្រើប្រាស់ទីន្នន័យត្រឹមឆ្នាំ ២០២១)ឬមូលដ្ឋានទិន្នន័យតែមួយឆ្នាំ។ខ្វះទិន្នន័យគោលសំខាន់មួយចំនួន។ទិន្នន័យមួយចំនួនពុំអាចប្រមូលបាននៅថ្នាក់មូលដ្ឋាន និងមានតម្រូវការការសម្របសម្រួល និងផ្តល់ទិន្នន័យពីថ្នាក់ជាតិ។ ការប្រៀបធៀបទិន្នន័យរវាងខេត្ត និងខេត្តនៅមានកម្រិត។ | -ស្នើសុំទិន្នន័យបច្ចុប្បន្នភាព របស់រដ្ឋបាលខេត្ត មន្ទីរ អង្គភាព រដ្ឋបាល ក្រុង ស្រុក ដែលពាក់ព័ន្ធ ដើម្បីរៀបចំ "ទិដ្ឋភាពសង្គម-សេដ្ឋកិច្ច និងការវិភាគ ភាពខ្លាំង, ភាពខ្សោយ, ឱកាស,និងការគំរាមគំហែង ដើម្បីកំណត់ពីសក្តានុពល និងបញ្ហាប្រឈមក្នុងកិច្ចអភិវឌ្ឍន៍របស់ខេត្តបាត់ដំបង ឆ្នាំ ២០២៦ " និងព័ត៌មានទូទៅ និងសូចនាករស្តីពី ស្ថានភាពសង្គម-សេដ្ឋកិច្ច ក្នុងខេត្តបាត់ដំបងឆ្នាំ២០២៦ " និង "មគ្គុទេសក៏សេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត សម្រាប់ឆ្នាំ២០២៦"<br>-ស្នើសុំក្រសួងផ្តល់មន្ត្រី និងប្រាក់ថវិកាឧបត្ថម្ភលើកទឹកចិត្តដល់ក្រុមការងារគេហទំព័រច្រើននាក់បន្ថែមទៀត។<br>-ស្នើសុំកញ្ចប់ថវិកាបន្ថែមសម្រាប់គាំទ្រការងារគេហទំព័រ និងបណ្តាញសង្គមមន្ទីរ<br>-ស្នើសុំវគ្គបណ្តុះបណ្តាលប្រមូល និងវិភាគទិន្នន័យបែបវិទ្យាសាស្ត្រ ដើម្បីគាំទ្រការងារគេហទំព័រ និងបណ្តាញសង្គមមន្ទីរ |
| **៣.ការិយាល័យថវិកា**<br>• **ការងារចំណូល-ចំណាយថ្នាក់ជាតិ៖** គ្មាន<br>• **ការងារចំណូលថ្នាក់ក្រោមជាតិ៖** មិនមាន<br>• **ការងារចំណាយថ្នាក់ក្រោមជាតិ៖** មិនមាន | ➢ គ្មាន<br>➢ មិនមាន<br>➢ មិនមាន |
| **៤.ការិយាល័យទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ៖**<br>• អង្គភាពមួយចំនួននៅមិនទាន់ធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋជាពិសេសរដ្ឋបាលឃុំ-សង្កាត់ | • ទាមទារការសហការជាមួយសាលាខេត្ត និងសុរិយោដីចុះទៅតាមមូលដ្ឋាន ដើម្បីជម្រុញការដាក់ពាក្យស្នើសុំធ្វើប័ណ្ណកម្មសិទ្ធលើដីរដ្ឋ |

| | |
|---|---|
| • អង្គភាពដែលបានដាក់ពាក្រស្នើសុំធ្វើប័ណ្ណកម្មសិទ្ធលើដីរដ្ឋហើយមិនបានផ្តល់ឯកសារបញ្ជាក់មកមន្ទីរសហវ | • ស្នើសុំអង្គភាពដែលបានដាក់ពាក្រស្នើសុំធ្វើប័ណ្ណកម្មសិទ្ធលើដីរដ្ឋហើយសូមផ្តល់ឯកសារបញ្ជាក់មកមន្ទីរសហវ<br>• ស្នើសុំអង្គភាពកាន់កាប់មេត្តាជំរុញការធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋអោយបានទាន់ពេលវេលា<br>• សំណូមពរ ៖ ស្នើក្រសួង ស្ថាប័ន មន្ទីរជំនាញ រដ្ឋបាលខេត្ត ក្រុង-ស្រុក ឃុំ-សង្កាត់ រៀបចំគៀរគរនូវទ្រព្យ<br>• សម្បត្តិ ដើម្បីចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ឱ្យបានត្រឹមត្រូវ តាមបទដ្ឋានគតិយុត្តជាធរមាន ។ |
| **<u>៥.ការិយាល័យលទ្ធកម្មសាធារណៈ</u>** : គ្មាន | គ្មាន |

## ៤. ទិសដៅបន្តអនុវត្តក្នុងខែ កញ្ញា ឆ្នាំ២០២៦

| <u>ទិសដៅបន្ត</u> | សប្តាហ៍ទី | | | |
|---|---|---|---|---|
| | ១ | ២ | ៣ | ៤ |
| **<u>១.ការិយាល័យរដ្ឋបាល ហិរញ្ញវត្ថុ និងបុគ្គលិក</u>**<br>➢ អនុវត្តចំណូល-ចំណាយថវិកាកម្មវិធីរបស់មន្ទីរតាមកម្មវិធីត្រីមាស ឆ្នាំ២០២៦<br>➢ ពង្រឹងវិន័យមន្ត្រីរាជការ, ម៉ោងបំពេញការងារ និងអនុវត្តតាមការណែនាំរបស់ក្រសួង<br>➢ <u>ត្រៀមរៀបចំកិច្ចប្រជុំជីវភាពប្រចាំខែរបស់មន្ទីរ</u><br>➢ <u>រៀបចំរបាយការណ៍ចំណាយថវិកា៩ខែដើមឆ្នាំរបស់មន្ទីរ</u><br>➢ <u>រៀបគម្រោងកម្មវិធីត្រីមាសទី៤ឆ្នាំ២០២៦របស់មន្ទីរ</u><br>➢ <u>ត្រៀមរៀបចំទូទាត់អាណ្ឌិតប្រជុំរបស់មន្ទីរ</u><br>➢ រៀបចំធ្វើបច្ចុប្បន្នភាពឯកសារ ដើម្បីរៀបចំស្នើសុំជម្រះនូវឯកសារដែលអស់សុពលភាពប្រើប្រាស់ និងឯកសារត្រូវយកទៅតម្កល់ | √ | √ | √ | √ |
| **២.ការិយាល័យស្ថិតិ និងសេដ្ឋកិច្ចមូលដ្ឋាន**<br>១.បន្តបូកសរុបរបាយការណ៍វឌ្ឍនភាពមន្ទីរប្រចាំខែកញ្ញា-ធ្នូ ឆ្នាំ២០២៦ សរុបជូនការិយាល័យរដ្ឋបាល ហិរញ្ញវត្ថុ និងបុគ្គលិក<br>២.រៀបចំទិន្នន័យព័ត៌មានសេដ្ឋកិច្ច និងសង្គមខេត្តបាត់ដំបងឆ្នាំ២០២៦ ឲ្យបានរួចរាល់ ១០០% នៅត្រីមាសទី ៣ ឆ្នាំ២០២៦។ និងបកប្រែជាភាសាអង់គ្លេស។<br>៣.រៀបចំមគ្គុទេសសេដ្ឋកិច្ច ឆ្នាំ២០២៦ ឲ្យបានរួចរាល់ ១០០% នៅត្រីមាសទី ៣ ឆ្នាំ២០២៦។និងបកប្រែជាភាសាអង់គ្លេស។ និងបញ្ចូលទិន្នន័យជា Mricrosoft Excel ដើម្បី upload ចូលគេហទំព័ររបស់មន្ទីរ។ | √ | √ | √ | √ |

| | | | | |
|---|---|---|---|---|
| ៤.រៀបចំរបាយការណ៍ភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែង ក្នុងកិច្ចអភិវឌ្ឍន៍ខេត្តបាត់ដំបង ឆ្នាំ ២០២៦( SWOT ) ឲ្យបានរួចរាល់ ១០០% នៅត្រីមាសទី៣ ឆ្នាំ២០២៦។ និងបញ្ចូលទិន្នន័យជា Microsoft Excel ដើម្បី upload ចូលគេហទំព័ររបស់មន្ទីរ។<br>៥.រៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល ឆ្នាំ២០២៧-២០២៩ របស់មន្ទីរជូនរដ្ឋបាលខេត្ត និងមន្ទីរផែនការខេត្ត ឲ្យបានរួចរាល់ ១០០% នៅត្រីមាសទី៣ ឆ្នាំ២០២៦។<br>៦.សហការណ៍គាំទ្រការងារនានា តាមសំណើសុំរបស់អគ្គនាយកដ្ឋានគោលនយោបាយក្នុងភូមិសាស្ត្រខេត្តបាត់ដំបង។ | | | | |
| **៣.ការិយាល័យថវិកា:**<br>**ការងាររដ្ឋបាលថ្នាក់ជាតិ** | √ | √ | √ | √ |
| ➢ ពិនិត្យ និងជំរុញបន្តទៀតនូវការអនុវត្តចំណូល-ចំណាយដើម្បីឆ្លើយតប និងកម្មវិធីត្រីមាសទី៣ឆ្នាំ២០២៦<br>➢ បន្តពិនិត្យ ការទូទាត់រជ្ជទេយ្យបុរេប្រទាន របស់មន្ទីរ អង្គភាពជំនាញឆ្នាំ២០២៦ | √ | √ | √ | √ |
| ➢ បន្តពិនិត្យ ការអនុវត្តធានាចំណាយតាមនីតិវិធីលទ្ធកម្មសាធារណៈរបស់មន្ទីរ អង្គភាពជំនាញ ឆ្នាំ២០២៦ | √ | √ | | |
| **ការងាររដ្ឋបាលថ្នាក់ក្រោមជាតិ**<br>➢ ពិនិត្យឯកសារបៀវត្សប្រចាំខែ និងឯកសារផ្សេងៗទៀតដូចជា ( ទូទាត់រជ្ជទេយ្យ,ទូទាត់ត្រង់, ទូទាត់លទ្ធកម្ម,...)របស់រដ្ឋបាលសាលាខេត្ត, និងមន្ទីរសុខាភិបាល<br>➢ រៀបចំរបាយការណ៍ បិទបញ្ជីចំណូល-ចំណាយឆ្នាំ២០២៥ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>➢ ជំរុញអង្គភាពរដ្ឋបាលខេត្ត អោយត្រៀមឯកសារស្នើសុំឧបត្ថម្ភគុណ្យភាពត្រីមាសបន្ត<br>➢ បន្តចុះសំណើរសុំគោលការណ៍, សំណើរសុំធានាចំនាយ, សំណើរសុំនិយ័តភាព, និងអាណត្តិ របស់រដ្ឋបាលសាលាខេត្ត,និងមន្ទីរសុខាភិបាលចូលក្នុងប្រពន្ធ័ FMIS | √ | √ | √ | √ |
| **៤.ការិយាល័យទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ:**<br>➢ បន្តការសហការជាមួយរដ្ឋបាលខេត្ត ដើម្បីជំរុញ និងបន្តការអនុវត្តការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងស្នើការអន្តរាគមន៍ដើម្បីការពន្លឿនការធ្វើបញ្ជីសារពើភណ្ឌគោល២០១៩ និងប្រៀបធៀបឆ្នាំ២០១៨ ២០២១ ២០២២ និង២០២៣<br>➢ បន្តការសហការជាមួយមន្ទីរសុរិយោដីខេត្តដើម្បីជំរុញការរៀបចំដាក់ពាក្យធ្វើប័ណ្ណកម្មសិទ្ធិ | √ | √ | √ | √ |
| **៥.ការិយាល័យលទ្ធកម្មសាធារណៈ:** | | | | |

**៥. សំណូមពរ**

- សូមស្នើសុំក្រសួងបន្តការបណ្តុះបណ្តាលផ្នែកការងារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (Non-tax Revenue Management Information System, NRMIS), ប្រព័ន្ធគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងបច្ចេកទេសដោះស្រាយបញ្ហាប្រឈមក្នុងការប្រើប្រាស់ប្រព័ន្ធ SARMIS ជំនាន់ថ្មីបន្តទៀត

**៦. សេចក្តីសន្និដ្ឋាន**

ការងារទាំងឡាយ របស់អង្គភាពតាមផ្នែកនីមួយៗ បានកំពុងធ្វើសកម្មភាពយ៉ាងមមាញឹក ដើម្បីឆ្លើយតបនឹងបទបញ្ញត្តិ និងបញ្ហាប្រឈមនានា។

អាស្រ័យដូចបានជម្រាបជូនតាមរបាយការណ៍ខាងលើសូម**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ និងគោរពជូនរបាយការណ៍ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ថ្ងៃ អង្គារ ៥កើត ខែ ស្រាពណ៍ ឆ្នាំមមី អដ្ឋស័ក ព.ស ២៥៧០
បាត់ដំបង, ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០២៦
**ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបាត់ដំបង**

**ប៉ោ ឡូ~ឡឿន**